# របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម

កម្មវិធីរបស់ the Asian International Justice Initiative

ឆ្នាំទី១ លេខ ២ សប្តាហ៍ទី ២ (០៦ ~ ០៩ មេសា ឆ្នាំ២០០៩)


## " សវនាការអង្គសេចក្តីលើករណីអតីតប្រធានមន្ទីរ ស.២១ កាំង ហ្កិចអាវ ហៅ ឌុច"



*លោក Francois Bizot ជាសាក្សីទី១ នៅក្នុងសវនាការជំនុំជម្រះអតីតប្រធាន ស-២១ ឌុច*

## ១. សេចក្តីសង្ខេប

ដំណើរការនីតិវិធីនៅសប្តាហ៍នេះផ្តោតទៅលើចរិកលក្ខណះរបស់ជនជាប់ចោទ និង ប្រវត្តិនៃការចូលរួមរបស់គាត់ក្នុងចលនាបក្សកុម្មុយនីស្តនៅប្រទេសកម្ពុជា ។ បន្ទាប់ពីការសួរដេញដោលដ៏សង្ខេបអំពីកុមារភាពរបស់**ឌុច** និង ការជាប់គុកជាបន្តបន្ទាប់ក្នុង នាមជាអ្នកទោសនយោបាយរួចមក អង្គជុំនំជម្រះ ចាប់ផ្តើមចោទសួរអំពីតួនាទីជាប្រធានរបស់គាត់នៅមន្ទីរ ម. ១៣ ដែលជាពន្ធនាគារបង្កើតឡើងក្នុងឆ្នាំ ១៩៧១ ដើម្បីសួរចំលើយ និងសម្លាប់អ្នកដែលគេចាត់ទុកថាជាខ្មាំងរបស់បក្ស។ ដោយអនុលោម តាមការកម្មវិធីណែនាំរបស់អង្គជុំនំជម្រះ បន្ទាប់ពីការចោទសួរលើ**ឌុច** សាក្សីពីរនាក់ គឺលោក **ហ្វ្រង់ស័រ បីស៊ូ** (*Francois Bizot)* និង លោក **អ៊ុច ស៊ន** ដែលធ្លាប់ជាប់នៅមន្ទីរនោះ បានផ្តល់សក្ខីកម្ម អំពី ម-១៣ ។ អង្គជុំនំជម្រះគ្រោងនឹងស្តាប់សក្ខីកម្មរបស់សាក្សី ផ្សេងទៀតអំពី ម-១៣ មុនឈានទៅការចោទសួរអំពីអង្គហេតុ ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ អំពីតួនាទីរបស់ជនជាប់ចោទនៅមន្ទីរ ស-២១។

ជារួម ដំណើរការនីតិវិធីបានបន្តយ៉ាងរលូននៅសប្តាហ៍នេះ បើទោះបីជាមានបញ្ហាបកប្រែខ្លះៗ ក៏ដោយ។ អ្នកបកប្រែត្រូវបានណែនាំ ក្នុងការប្រាប់ដល់ភាគី និងសាក្សីឱ្យនិយាយក្នុងល្បឿនសមស្រម និងច្បាស់ ព្រោះថា ពេលខ្លះការដាស់តឿនអំពីបញ្ហា នេះពីសំណាក់អង្គជុំនំជម្រះមិនបានធ្វើគ្រប់ពេលនោះទេក្នុងពេលកំពុងសាកសួរ ។

## ២. បញ្ហាច្បាប់ និងនីតិវិធី

### ក. សក្ខីកម្មរបស់ជនជាប់ចោទ និង សាក្សី

#### ១. ជនជាប់ចោទ កាំង ហ្កេច អ៊ាវ ហៅ ឌុច

***ការចោទសួរ ឌុច លើបញ្ហានានា ពាក់ព័ន្ធមន្ទីរ ម -១៣:*** ការផ្តល់សក្ខីកម្មរបស់ឌុចអំពីការបង្កើត និងដំណើរការនៅមន្ទី ម-១៣ បានចំណាយពេលស្ទើតែ ៣ ថ្ងៃក្នុងសប្តាហ៍នេះ ។ បើទោះបីជា បញ្ហាដំណើរការប្រព្រឹត្តទៅរបស់ ម-១៣ ស្ថិតនៅក្រៅសមត្ថកិច្ចរបស់អង្គជុំនំជម្រះក៏ដោយ ក៏ប្រធានអង្គជុំនំជម្រះលោក **និល ណុន** បានសំរេចថា ការផ្តល់សក្ខីកម្មរបស់ **ឌុច** មានភាពជាប់ពាក់ព័ន្ធ និងសំខាន់ ក្នុងការជួយពន្យល់ និងបំភ្លឺពីបរិបទ រចនាសម្ព័ន្ធអង្គការ និងមុខងារប្រតិបត្តិនៃ មន្ទីរ ស-២១ ។

***គោលបំណង និងរចនាសម្ព័ន្ធនៃការបញ្ជា :*** **ឌុច**បានរៀបរាប់អំពីតំបន់ដែលកាន់កាប់ដោយ ម-១៣ និងមុខងារប្រតិបត្តិរបស់ ម-១៣។ គាត់បានពន្យល់ថា ម-១៣ ត្រូវបានបែងចែក ជាពីរតំបន់ផ្សេងគ្នា ដែលមានឈ្មោះថា ម-១៣(ក) និង ម-១៣(ខ)។ គាត់បានបន្ថែមថា ម-១៣(ក) បានផ្លាស់ប្តូរទីតាំងជាច្រើនលើក និង បានប្រព្រឹត្តទៅក្រោមការគ្រប់គ្រងផ្ទាល់របស់គាត់។ ចំណែកឯ ម-១៣(ខ) ត្រូវបានគ្រប់គ្រងដោយអនុប្រធានរបស់គាត់ឈ្មោះ មិត្ត "**ស៊ុម**"។

**ឌុច** បានឱ្យដឹងថា បេសកម្មរបស់គាត់នៅ ម-១៣ រួមមាន " *វាយ សួរចម្លើយ និងកំទេច*" ទៅលើ **គិញ** ដែលគាត់ចាត់ ទុកថាមកពីទឹកដីរបស់ **លន់ ណុល**។ គាត់បានទទួលស្គាល់ថា "ការកំទេច គឺជាគោលការណ៍ចំបងនៅឯម-១៣(ក)" និងបានពន្យល់ថា កាតព្វកិច្ចអនុវត្តន៍បេសកម្មរបស់គាត់នៅ ម១៣ គឺមធ្យោបាយការពារតំបន់រំដោះ និងប្រជាជនរបស់គាត់។ ឌុចក៏បានលើកឡើងពីគោលបំណងរបស់ម-១៣ គឺជាការសំរុះសំរួលតាមតំរូវការបដិវត្តន៍។

សហព្រះរាជអាជ្ញាអន្តរជាតិលោក **រ៉ូប៊ែរ ពីទី** បានលើកសំអាងថា "ម-១៣ ជាមជ្ឈមណ្ឌលហ្វឹកហ្វឺនមូលដ្ឋានមួយ ដែលឌុចធ្វើការសំលៀងជំនាញរបស់ខ្លួនក្នុងនាមជាប្រធានគុក"។ ជាពិសេស សំណួររបស់លោក **រ៉ូប៊ែរ** បានតាំងឡើង ដើម្បីចំរាញ់យកព័ត៌មានអំពីយុទ្ធសាស្ត្រជ្រើសរើសបុគ្គលិករបស់ឌុច និងប្រព័ន្ធទទួលចម្លើយសារភាពនៅ ម-១៣។

ចំពោះអង្គហេតុដែលថា ឌុច ជាប្រធាន ម-១៣ មេធាវីការពារក្តីអន្តរជាតិលោក **ហ្វ្រង់ស័រ រូ** បានបង្ហាញភស្តុតាង ដែលគាំទ្រនូវអំណះអំណាងរបស់គាត់ថា សម័យកម្ពុជាប្រជាធិបតេយ្យត្រូវបានជួយទ្រទ្រង់ដោយ ***"គោលការណ៍ពីរ គឺ ភាពភ័យខ្លាច និង ការសម្ងាត់"***។ ជាការឆ្លើយតបទៅនឹងសំណួររបស់លោក **ហ្វ្រង់ស័រ រូ** ឌុចបានទទួលស្គាល់ថា *"មនុស្សគ្រប់រូប នៅក្នុងបក្សត្រូវគោរពបទបញ្ជា ប្រសិនបើអ្នកណាមិនគោរពបញ្ជា អ្នកនោះអាច ប្រឈមមុខនឹងការបាត់បង់អាយុជីវិត"* ។ ឌុចបានឱ្យដឹងទៀតថា ភាពភ័យខ្លាចនៅសម័យខ្មែរក្រហម គឺជាបញ្ហារបស់ **ប៉ុល ពត**។ ឌុចបានដឹងថា ការគោពការសំងាត់គឺ *"យើងរក្សាអ្វីៗទាំងអស់ជាការសម្ងាត់។ រាល់ការងារទាំងអស់ ត្រូវតែរក្សាការសំងាត់"*។ ឌុច ក៏បាននិយាយអំពីការចូលរួមរបស់គាត់ជាប្រចាំ នៅក្នុង "ការប្រជុំជីវភាពបក្ស"។

***អ្នកទោស និងលក្ខខណ្ឌនៃការឃុំខ្លួន :*** ឌុចបានទទួលស្គាល់ថា អ្នកទោសនៅ ម-១៣ ត្រូវបានធ្វើទារុណកម្មដោយលក្ខខណ្ឌ ***"អមនុស្សធម៌"*** ពួកគេមិនមានអាហារគ្រប់គ្រាន់ អនាម័យ និងថ្នាំសង្កូវ...។ សំណួរដោយលំអិតពីសំណាក់អង្គជំនុំជម្រះ និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក៏បានឱ្យដឹងដែរថា អ្នកទោសត្រូវបានដកហូតមធ្យោបាយលាងសំអាតខ្លួន ការដាក់ខ្នោះច្រវ៉ាក់ និងបង្ខំឱ្យធ្វើការជាទម្ងន់។

***វិធីសាស្ត្រ និងមធ្យោបាយនានានៃការសួរចម្លើយ*** ៖ ឌុច មិនបានបង្ហាញនូវអារម្មណ៍រំជើបរំជួលទេ ដោយគាត់បានសារភាពទទួលស្គាល់ការចូលរួមធ្វើទារុណកម្ម ក្នុងនាមគាត់ជាប្រធាន ម-១៣។ គាត់បានបន្តនូវសភាពស្ងៀមស្ងាត់ថា គាត់បានផ្ដល់ការណែនាំនូវបច្ចេកទេសធ្វើទារុណកម្មដោយខ្លួនឯង ដើម្បីទាញយកចម្លើយសារភាព ដូចជាការវាយចិញ្ច្រាំយកចម្លើយ ការចងស្លាបសេកអ្នកទោស និងការដាក់ឱ្យហាលត្រូវខ្យល់ត្រជាក់។ សំខាន់ជាងនេះទៀត ការពិពណ៌នាអំពីបច្ចេកទេសធ្វើទារុណកម្មរបស់គាត់ធ្វើនៅ ម-១៣ គឺរក្សានូវការបំភ្លឺមួយដែលមានភាពប្រហាក់ប្រហែលគ្នារវាងពន្ធនាគារនេះ និង មន្ទីរ ស-២១។

ការផ្ដល់សក្ខីកម្មរបស់ឌុចពេញមួយសប្ដាហ៍នេះ បញ្ជាក់ថា គាត់មិនចង់ និងទោមនស្សទៅនឹងការ តែងតាំងតួនាទីគាត់ជាប្រធាននៅ ម-១៣។ ទោះបីជាយ៉ាងណា គាត់បានពិពណ៌នាខ្លួនឯងថា ***"នៅក្នុងរបបនោះ ខ្ញុំមិនឃើញមានជំរើសអ្វីក្រៅពីការគោរពវិន័យបក្សនោះទេ"***។ សំខាន់ជាងនេះទៀត ឌុចបានរំជួលចិត្ត នៅពេលធ្វើសក្ខីកម្មជាមួយបទសម្ភាសន៍ ដែលគាត់បានផ្ដល់នៅដំណាក់កាលចៅក្រមស៊ើបអង្កេត កាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៧។ ចៅក្រម **ឡាវីង** បានអាននូវ កំណត់ហេតុនោះដែលបង្ហាញឱ្យឃើញនូវ "ក្ដីអស់សង្ឃឹមរបស់ឌុច" ជាមួយតួនាទីនៅ ម-១៣។ លិខិតមួយ ក៏បង្ហាញថាគាត់បានស្វែងរកការលួងលោមចិត្ត តាមរយៈការសូត្រកំណាព្យភាសាបារាំងមួយ។ គួរគត់សំគាល់ថា ឌុចដកដង្ហើមថប់ៗ ដោយបញ្ចេញនូវកង្វល់ និងភាពមិនសប្បាយចិត្តនៅពេលប្រឈមមុខជាមួយ នឹងបទឧក្រិដ្ឋធ្ងន់ធ្ងរ ដែលកើតឡើងក្រោមបញ្ជារបស់គាត់។

២. **លោក ហ្វ្រង់ស័រ ប៊ីសូរ ៖**

នៅរសៀលថ្ងៃពុធ អង្គជំនុំជម្រះបានកោះហៅសាក្សីដំបូងឈ្មោះ **ហ្វ្រង់ស័រ ប៊ីសូរ** ជាអ្នកស្រាវជ្រាវ អាយុ ៦៩ ឆ្នាំបច្ចុប្បន្នរស់នៅភាគខាងជើងប្រទេសថៃ។ គាត់ត្រូវបានចាប់ខ្លួនដោយទាហានខ្មែរក្រហម នៅខែតុលា ឆ្នាំ១៩៧១ និងឃុំខ្លួននៅ ម-១៣ រយៈពេលបីខែ។ នៅឆ្នាំ២០០៣ **ប៊ីសូរ** បានសរសេរសៀវភៅមួយក្បាលមានចំណងជើងថា **"The Gate"** ដែលរ៉ាយរ៉ាប់អំពីអារម្មណ៍ និងបទពិសោធន៍នៅ ម-១៣។ គួរឱ្យកត់សំគាល់ថា សេចក្ដីដកស្រង់ពីសៀវភៅ "The Gate" ត្រូវបានអានដោយចៅក្រម និងភាគី ក្នុងដំណើរការផ្ដល់សក្ខីកម្មរបស់គាត់។

ការផ្ដល់សក្ខីកម្មក្នុង ***"នាមជាអ្នកទោស"*** នៅ ម-១៣ **ប៊ីសូរ** បានរ៉ាយរ៉ាប់អំពីលក្ខខណ្ឌនៃការឃុំខ្លួន និងបច្ចេកទេសនៃការសួរចម្លើយ ដែលបានធ្វើនៅអាគារដ៏មានសុវត្ថិភាពមួយ។ លោក ប៊ីសូរ ត្រូវបានចោទថាជា គិញ ស៊ី អាយ អេ និងត្រូវបានសួរចម្លើយជារៀងរាល់ថ្ងៃដោយឌុចខ្លួនឯង តែ ***"ក្នុងលក្ខណៈត្រជាក់"*** ។ **ប៊ីសូរ** បានទទួលស្គាល់ថា ការជួបជាមួយឌុច ជារៀងរាល់ថ្ងៃ បានបង្កើតជាភាព ***"ស្និតស្នាល"*** និងបង្កើតជាភាពជាមនុស្សធម៌រវាងពួកគេ។ ទោះបីជា គាត់មិនដែលឃើញ និងមានពិសោធន៍ដោយត្រូវបានវាយក៏ដោយ តែគាត់បានដឹងថា អ្នកយាមបានប្រើវិធីនេះ ដើម្បីឱ្យអ្នកទោសទាំងនោះផ្ដល់ចម្លើយ។ ចំពោះលក្ខខណ្ឌនៃការឃុំឃាំងនៅ ម-១៣ **ប៊ីសូរ** បានសង្កត់ធ្ងន់ថា ការស្លាប់ជាញឹកញាប់ដោយជំងឺគ្រុនចាញ់ ដែលមិនអាចទប់ស្កាត់បាន។ **ប៊ីសូរ** ទទួលស្គាល់ថា គាត់ជាអ្នកទោសពិសេស ក្នុងចំណោមអ្នកទោសទាំងនោះ ហើយគាត់បានទទួលនូវបុព្វសិទ្ធិសមរម្យ ដែលអ្នកផ្សេងមិនមាន គឺការបរិភោគ ដូចជា បាយគ្រប់គ្រាន់តាមតំរូវការ និងមុជទឹកជារៀងរាល់ថ្ងៃ នៅស្ទឹងក្បែរនោះ។

សហព្រះរាជអាជ្ញាលោក **រ៉ូប៊ែរ** បានសួរសំណួរទាក់ទងនឹងការធ្វើសេចក្ដីសន្និដ្ឋានរបស់ **ប៊ីសូរ** ដែលឌុចគិត ថាការងាររបស់គាត់

***"គួរឱ្យស្អប់ខ្ពើម"***។ លោក **រ៉ូប៊ែរ** បានស្នើសូមឱ្យ **ប៊ីសូរ** ប្រមូលនូវភាពមិនសុខស្រួលម្តងទៀត ដោយមិនផ្អែកទៅតាមអារម្មណ៍ កុំឱ្យផ្ទុយនឹងអង្គហេតុ។ នៅពេលមេធាវីការពារក្តី **ហ្វ្រង់ស័រ រ៉ូ** សួរសំណួរ លោក **ប៊ីសូរ**បានបញ្ជាក់ថា ឌុចត្រូវបានបង្ខាំងនៅក្នុងសម័យកាលមួយដែលគួរឱ្យភ័យខ្លាច ***"ដែលជាសម័យងងឹតសូន្យសុង"***។ លោក **ប៊ីសូរ** បានពិពណ៌នាពីរបៀបដែល ឌុច ខ្លួនឯងរស់នៅដោយមានការភ័យខ្លាចពីមេរបស់ខ្លួន។ សំខាន់ជាងនេះទៀតលោក **ហ្វ្រង់ស័រ រ៉ូ** បានសំដែងពីការពេញចិត្តសំរាប់ការចូលរួមចំណែកដ៏ធំធេងរបស់លោក ប៊ីសូរ ***"ដែលបានផ្តល់នូវការងារយុត្តិធម៌"*** ដោយការទទួលស្គាល់ភាពមនុស្សធម៌ក្នុងការគោរពចំពោះឌុច។

៣. **<u>លោក អ៊ុច ស៊ន</u>** :

នៅព្រឹកថ្ងៃព្រហស្បតិ៍ អង្គជំនុំជម្រះបានកោះហៅសាក្សីអាយុ ៧២ ឆ្នាំម្នាក់ឈ្មោះ **អ៊ុច ស៊ន** ដែលត្រូវបានឃុំខ្លួននៅ ម-១៣ ពីខែមិនា ១៩៧៣ រហូតដល់ឆ្នាំ ១៩៧៤។ អង្គជំនុំជម្រះ មានការភ័ន្តច្រលំខ្លះពីដំបូងនូវអត្តសញ្ញាណ របស់ **អ៊ុច ស៊ន** តែការភ័ន្តច្រលំនេះត្រូវបានដោះស្រាយ និង ការសួរសំនួរ និងស្តាប់ចំលើយសាក្សីត្រូវបានបន្តដូចដែលបានគ្រោងទុក។

សក្ខីកម្មរបស់ **អ៊ុច ស៊ន** ទាក់ទងជាបឋមទៅនឹងស្ថានភាពនៃការឃុំខ្លួន និងបច្ចេកទេសនៃការសួរចំលើយដែលត្រូវបានប្រើប្រាស់នៅម.១៣ ដែលគាត់ធ្លាប់បានមើលឃើញនូវ "ការធ្វើទារុណកម្មគ្រប់បែបយ៉ាងទៅលើអ្នកទោស" និងធ្វើឱ្យគាត់មានភាពតក់ស្លុតជាខ្លាំង។ ដោយត្រូវបានរងការចោទ ប្រកាន់ថាជា" គិញ" គាត់បានផ្តល់សក្ខីកម្មទាក់ទងនឹងអ្នកទោសដែលត្រូវបានដាក់ខ្នោះនៅក្នុងរណ្តៅ និងការបង្អត់អាហារ។ គាត់ ក៏បានធ្វើការបញ្ជាក់ទៅលើសក្ខីកម្មរបស់លោក Bizot អំពីទារុណកម្មដ៏ឃោឃៅនៅម-១៣ ។ ម៉្យាងទៀត គាត់ថែមទាំងបាន ពន្យល់អំពីការសម្លាប់ចំនួន ២ ករណីដោយសង្ខេប ដែលគាត់បានឃើញនៅម-១៣ ។

គួរឱ្យកត់សំគាល់ថា សក្ខីកម្មរបស់គាត់មានភាពខុសប្លែកពីសក្ខីកម្មរបស់ **ឌុច** ទាក់ទងនឹងបច្ចេកទេសនៃការសួរចំលើយដែលបានប្រើប្រាស់នៅម.១៣។ គាត់បានផ្តល់សក្ខីកម្មដោយច្បាស់លាស់ថា ការជ្រមុជទឹកអ្នកទោស និង ការដកក្រចក គឺជាបច្ចេកទេសដែលត្រូវបានប្រើជាញឹកញាប់សំរាប់ដាក់ទោសលើអ្នកទោស។ ទោះជាយ៉ាងណាក៏ដោយ ភ្លាមៗដែលគាត់បាននិយាយដូច្នេះ **ឌុច** បានលើកពីសច្ចភាពពិតនៃការចោទប្រកាន់នោះ និងបានបញ្ជាក់ម្តងទៀតនូវជំហររបស់គាត់ថា ការអនុវត្តបែបនេះ គឺមិនមានទេនៅម.១៣ ។ យ៉ាងណាក៏ដោយ **ឌុច** បានយល់ព្រមនឹងសក្ខីកម្មរបស់ **អ៊ុច ស៊ន** ថាជា "ការត្រឹមត្រូវជាមូលដ្ឋាន"។ ទោះជាយ៉ាងនេះក្តី នៅពេលសួរបញ្ជាក់អំពីចំនួនតួលេខនៃអ្នកទោស សក្ខីកម្មរបស់ **អ៊ុច ស៊ន** មានភាពមិនច្បាស់លាស់ និង ខ្ជាប់ខ្ជួនទេ ។

បង្ហាញអំពីអារម្មណ៍របស់គាត់ចំពោះរបបប៉ុល ពត **អ៊ុច ស៊ន** បានបញ្ជាក់ថា "គាត់មិនយល់ហេតុអ្វីក៏ខ្មែរកាប់សំលាប់ខ្មែរគ្នាឯង"។ នៅពេលចៅក្រម **Lavergne** ប្រទល់មុខ **ឌុច** ចំពោះសេចក្តីថ្លែងនេះ គាត់បានពន្យល់ថា ដោយសារតែតួនាទីការនយោបាយក្នុងការកំទេច " គិញសត្រូវ"។ នៅពេលចៅក្រម **Lavergne** សួរថាតើគាត់នៅខ្លាច **ឌុច** ទៀតទេ ពេលនេះ **អ៊ុច ស៊ន** បានឆ្លើយថាលែងខ្លាចទៀតហើយ ព្រោះ" គាត់គឺជាខ្លាអស់ចង្កូមហើយ" ។

### ខ. អំណះអំណាង / កង្វល់ដែលបានលើកឡើងនាពេលសវនាការ :

***ការអង្គុយរបស់សាក្សីនៅក្នុងបន្ទប់សាធារណៈ មុនពេលផ្តល់សក្ខីកម្ម*** ៖ វិធាន ៨៨(២) នៃវិធានផ្ទៃក្នុង តំរូវថា អ្នកជំនាញ និងសាក្សី ត្រូវស្ថិតនៅក្នុងបន្ទប់ផ្សេងដែលមិនអាចមើលឃើញពីកិច្ចដំណើរការនីតិវិធីនៅក្នុងបន្ទប់សវនាការ មុនពេលផ្តល់សក្ខីកម្ម។ វិធាននេះ ត្រូវបានបំពាននៅក្នុងដំណើរការនីតិវិធីនៅថ្ងៃអង្គារ៍ ដែលយ៉ាងហោចណាស់សាក្សីមួយនាក់ ដែលបានគ្រោងថានឹងត្រូវផ្តល់សក្ខីកម្មនាពេលសវនាការនេះ ត្រូវបានរកឃើញថាបានអង្គុយនៅក្នុងបន្ទប់សាធារណៈ។ ដោយយោងតាមសំណើររបស់មេធាវីការពារក្តី Francoix Roux ប្រធានអង្គជំនុំជម្រះ បានប្រកាសថា លោក-លោកស្រីជាសាក្សី មិនអនុញ្ញាតិឱ្យអង្គុយមើលដំណើរការនីតិវិធី នៅក្នុងបន្ទប់សវនាការនេះទេ និងសូមឱ្យចាកចេញទៅក្នុងបន្ទប់រង់ចាំ។ យ៉ាងហោចណាស់ មនុស្សមួយនាក់បានចាកចេញពីបន្ទប់សវនាការជាសាធារណៈ នាពេលនោះ។

ប្រធានអង្គជំនុំជម្រះ ហាក់ដូចជាបានសំដែងយោបល់ថា អង្គភាពគាំពារសាក្សី និង អ្នកជំនាញ គួរតែទទួលខុសត្រូវក្នុងការបង្ការការកើតឡើងផ្ទួនៗ នៃការបំពាននឹងវិធាន ៨៨(២)។ ទោះជាយ៉ាងណាកដោយ ក្រៅពីបានប្រកាសបែបនេះ អង្គជំនុំជម្រះខ្លួនឯង បានខកខាន ក្នុងការធានា និងបញ្ជាក់ថាសាក្សីទាំងនោះបានចាកចេញពីបន្ទប់សាធារណៈឬអត់ ដែលនេះវាអាចជាបញ្ហាមួយជះឥទ្ធិពលដោយផ្ទាល់ចំពោះ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធមិរបស់ជនចាប់ចោទ **ឌុច** ។ គួរកត់សំគាល់ថា ក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជា ក៏មានចែងនូវបញ្ញតិប្រហាក់ប្រហែលគ្នាទៅនឹងវិធាននេះដែរ[១] ។

***ការប្រើប្រាស់ឯកសារគតិយុត្តបន្ថែម*** ៖ មុនពេលចាប់ផ្តើម ការសួរសំនួរដល់ជនជាប់ចោទ នៅសប្តាហ៍នេះ ប្រធានអង្គជំនុំជម្រះ **និល ណុន** បានអានបញ្ជីឯកសារ ដែលជាប់ទាក់ទងនឹងសក្ខីកម្មរបស់ **ឌុច** នៅម-១៣។ ក្រោយពីការអានចប់ មេធាវីការពារក្តី François Roux បានលើកឡើងថា ឯកសារមួយក្នុងបញ្ជីនេះ ដែលជាសេចក្តីថ្លែងដោយ **ឌុច** ទៅកាន់លោក Christophe Peschoux មិនគួរយកមកប្រើប្រាស់នៅក្នុងករណីនេះ ដោយវាធ្វើឱ្យខូចប្រយោជន៍កូនក្តីរបស់គាត់[២]។ លោក Roux បានលើកឡើងពីកាលៈទេសៈ ដែលការសម្ភាសន៍បានធ្វើឡើង ជាពិសេស អំពីកម្មវត្ថុរបស់អ្នកសម្ភាសន៍ និង ការចូលរួមរបស់អ្នកបកប្រែ។ ជាងនេះទៅទៀត Roux បានបញ្ជាក់ថា ក្នុងខណៈពេលនៃការសម្ភាសន៍ **ឌុច** មិនបានគិតដល់ថាប្រើប្រាស់ឯកសារនេះ ជាឯកសារគតិយុត្តនោះទេ ។ ជាការឆ្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិ លោក Robert Petit បានតតាំងថា "តុលាការ មានសេរីភាពក្នុងការពិចារណារលើភស្តុតាងពាក់ព័ន្ធ ដែលបានផ្តល់ ដែលមិនផ្ទុយនឹងផលប្រយោជន៍នៃយុត្តិធម៌" ។ អង្គជំនុំជម្រះ បានអញ្ជើញភាគីទាំងអស់ដាក់សេចក្តីសន្និដ្ឋានជាលាយល័ក្ខអក្សរចំពោះបញ្ហានេះ ដើម្បីដោះស្រាយបញ្ហានេះ។

## ៣. ការចូលរួមរបស់ជនរងគ្រោះ និង ការការពារ និងគាំទ្រសាក្សី និងជនរងគ្រោះ

***វត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសិទ្ធិទទួលបានមេធាវីតំណាង*** ៖ ទំនោរនៃការថយចុះវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណីកាលពីសប្តាហ៍មុន ត្រូវបានបន្តរហូតមកដល់សប្តាហ៍នេះ ដែលសវនាការត្រូវបានចូលរួមដោយដើមបណ្តឹងរដ្ឋប្បវេណីមិនលើសពី

---

[1] ជាពិសេស មាត្រា ៣២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា បានតំរូវថា អ្នកជំនាញ និងសាក្សី ថយខ្លួនទៅនៅក្នុងបន្ទប់រង់ចាំដែលទុកបំរុងឱ្យខ្លួន ហើយដែលពីក្នុងបន្ទប់រង់ចាំនោះ ខ្លួនមិនអាចមើលឃើញ ឬ ឮអ្វីដែលប្រព្រឹត្តទៅនៅក្នុងបន្ទប់សវនាការទេ ។

[2] លោក Christophe Peschoux បច្ចុប្បន្នជាតំណាងការិយាល័យឧត្តមស្នងការរបស់អង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ។

៧ នាក់ អង្គុយនៅក្នុងបន្ទប់សវនាការ [3]។

***អង្គជំនុំជម្រះបដិសេធសំណើររបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីឆ្លើយតបនឹងបញ្ហាដីកាឃុំខ្លួនបណ្តោះអាសន្ន និង ធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់*** ៖ ដូចដែលបានកត់សំគាល់នៅក្នុងរបាយការណ៏កាលពីសប្តាហ៏មុន មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានសុំការអនុញ្ញាតិធ្វើសេចក្តីសន្និដ្ឋាន ចំពោះការដោះលែងជនជាប់ចោទពីការឃុំខ្លួនបណ្តោះអាសន្ន ក៏ដូចជាឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានបើករបស់សហព្រះរាជអាជ្ញា។ នៅថ្ងៃច័ន្ទ អង្គជំនុំជម្រះ បានចេញសេចក្តីសំរេចបដិសេធសំណើរសុំទាំងពីរខាងលើនេះ ដោយថា វាអាចពង្រីកសិទ្ធិក្នុងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ជាពិសេស អង្គជំនុំជម្រះបដិសេធសំណើទាំងពីរ នៅក្នុងមូលដ្ឋានថា សំណើទាំងនេះមិនត្រូវបានគាំទ្រដោយវិធានផ្ទៃក្នុងនោះទេ។

***ការសាកសួរជនជាប់ចោទ និងសាក្សី*** ៖ តាមវិធាន ៩០(២) និងវិធាន ៩១ នៃវិធានផ្ទៃក្នុង បានចែងពីសិទ្ធិរបស់ដើមរដ្ឋប្បវេណីក្នុងការសាកសួរជនជាប់ចោទ និងសាក្សីនានា។ អង្គជំនុំជម្រះបានកំណត់ថា លំដាប់លំដោយនៃការសាកសួរមានដូចតទៅ ៖ ជាបឋម ការសាក្សសួរធ្វើឡើងដោយសហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីការពារក្តីជនជាប់ចោទ [4]។ កំឡុងដំណើរការក្តីនាសប្តាហ៏នេះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានផ្តល់សិទ្ធិអោយសាកសួរជនជាប់ចោទ និងសាក្សី ២នាក់ ដែលត្រូវបានកោះហៅនៅចំពោះមុខអង្គជំនុំជម្រះ ជាអាទិ៏មាន លោក ហ្វ្រង់ស្វ័រ ប៊ីស៊ូ និងលោក អ៊ុច សន។ អង្គជំនុំជម្រះបានផ្តល់សិទ្ធិដល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្នុងការសាកសួរនេះ។

តំណាងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤ក្រុម ដែលមានសមាសភាពទាំងមេធាវីជាតិ និងអន្តរជាតិ ដែលជាទូទៅត្រូវបានគេមើលឃើញថា ដំណើរការបានល្អនៅពេលដែលដាក់សំណួរចោទទៅសាក្សី កំឡុងពេលដំណើរការក្តីនាសប្តាហ៏នេះ។ ជាក់ស្តែង មានសំណួរមួយចំនួនត្រូវបានសួរដោយព័ត៌មានផ្ទាល់ពីភាគីដើមបណ្តឹងរដ្ឋប្បវេណី ឬសួរបញ្ជាក់អំពីការរំពឹងទុករបស់ជនរងគ្រោះ។ នៅក្នុងករណីនេះ លោកមេធាវីក្រុម ៣ Philippe Canone បានសួតរទៅលោក Bizot អំពីអ្វីដែលគាត់បានគិត និង អ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីអាចរំពឹងទុកពីការជំនុំជម្រះនេះ។ តែទោះជាយ៉ាងណាក៏ដោយ ពេលខ្លះសំណួរហាក់ដូចជាច្រំដែលៗ ហើយយកចិត្តទុកដាក់ខ្លាំងតែទៅលើសំណួរដែលមិនចំគោលដៅ ជាជាងផ្តោតការយកចិត្តទុកដាក់លើសំណួរគន្លឹះសំខាន់ៗ។ ខណៈដែលអង្គជំនុំជម្រះ បានស្នើសុំដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនដង ដើម្បីចៀសវាងការសួរសំណួរច្រំដែលៗ ឃើញមានតែ២លើកប៉ុណ្ណោះ ដែលអង្គជំនុំជម្រះបានអន្តរគមន៏ជាក់ស្តែង ដើម្បីរារាំងការសួរសំណួរដែលបានឆ្លើយពីមុនរួចហើយ។ សេចក្តីត្រូវការពេលវេលាបន្ថែមត្រូវបានផ្តល់អោយ ដោយហេតុថា អង្គជំនុំជម្រះបានជួបប្រទះនូវបទពិសោធន៏ការពិបាកផ្នែកបកប្រែភាសា

[3] នៅក្នុងសប្តាហ៏នេះ ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ១ ត្រូវបានតំណាងដោយមេធាវី ទី ស្រ៊ីនណា និងលោក Alain Werner និងក្រុម ៣ ដោយ ក. ម៉ុច សុវណ្ណារី និងលោក Philippe Canone។ ខណៈដែល ក្រុម ២ ត្រូវបានតំណាងដោយខ្ជាប់ខ្ជួនដោយមេធាវីយ៉ាងហោចណាស់ ៣ នាក់ គឺ លោកមេធាវី គង់ ពិសី ឬ ផ្លាស់ប្តូរជាមួយលោក យ៉ុង ផានិត លោក ហុង គីមសួន និង Silke Studzinsky ចំណែកឯក្រុម ៤ ត្រូវបានតំណាងដោយមេធាវីជាតិតែមួយនាក់ គឺ លោក ហុង គីមសួន ឬ លោក គង់ ពិសី ។ ចំពោះលោក Pierre Olivier Sur បានអវត្តមានពេញមួយសប្តាហ៏ ។

[4] ការកំណត់នេះ ត្រូវបានធ្វើឡើងដោយសេចក្តីណែនាំស្តីពីកម្មវិធីជំនុំជម្រះ ចុះថ្ងៃទី ២០ មិនា ២០០៩។

ដែលកើតមានជាបន្ត ដែលមានន័យថា អង្គជំនុំជំរះមិនប្រាកដថាភាគីនានាបានយល់នូវសំណួរដែលបានសួរលើកទី១នោះទេ។ នៅពេលសាកសួរទៅកាន់ជនជាប់ចោទ អង្គជំនុំជម្រះបានស្នើសុំដល់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីចំនួន២ក្រុម គឺក្រុម២ និង ៤ ឱ្យបញ្ចប់ការសួរចម្លើយក្នុងរយៈពេល១ម៉ោង។

***ភាពគ្រប់គ្រាន់នៃយន្តការការពារសាក្សី*** **:** កម្រិតដែលអង្គជំនុំជម្រះនឹងបន្តប្រើវិធានការការពារសាក្សី និងវិធីដែលគេនឹងកំណត់នៅពេលប្រើវិធានការទាំងនេះ នៅតែមានន័យមិនប្រាកដនាសប្ដាហ៍នេះ ដោយសារថា សាក្សីទាំង២ដែលផ្ដល់សក្ខីកម្មបានធ្វើឡើងជាសាធារណៈ បើទោះបីជារហស្សនាមត្រូវបានប្រើជំនួសឈ្មោះរបស់គេ រហូតដល់ដំណាក់កាល ដែលគេចូលទៅក្នុងបន្ទប់សវនាការក៏ដោយ។ ថ្វីបើអ្នកឃ្លាំមើលដំណើរការសវនាការបានស្វាគមន៍ជាការពិតថា សាក្សីបានផ្ដល់សក្ខីកម្មក្នុងសវនាការដោយបើកចំហក៏ដោយ ក៏មានការពន្យល់ខ្លះៗចំពោះមូលហេតុដែលនាំឱ្យរហស្សនាមត្រូវបានគេបោះបង់ចោល ជាពិសេសដោយសារសាក្សីទាំង២ គឺជាអតីតអ្នកជាប់ឃុំឃាំងនៅម-១៣។ ជាក់ស្ដែង មិនមានការបង្កើតពិធីការសម្រាប់អោយសាក្សី បញ្ជាក់ពីការស្បថមុនពេលផ្ដល់សក្ខីកម្មនោះទេ ក្នុងនោះលោក Bizotបានធ្វើការស្បថក្នុងបន្ទប់សវនាការមុនពេលផ្ដល់សាក្សីកម្ម ចំណែកឯលោក **ស៊ន** មិនបានធ្វើការបញ្ជាក់ស្បថនោះទេ។ អ្នកឃ្លាំមើលដំណើរការសវនាការបានសង្កេតឃើញថា សាក្សីខ្មែរបានធ្វើការស្បថនៅពីមុខរូបសំណាក នៅពីមុខសាលាក្ដីនៅពេលថ្មីៗនាសប្ដាហ៍នេះ ប៉ុន្តែមិនមានការបញ្ជាក់ទេកំឡុងពេលដំណើរការក្ដី ដែលថាលោក **ស៊ន** គឺជាសាក្សីមួយក្នុងចំណោមសាក្សីបានស្បថទាំងនេះ។ លើសពីនេះទៀត នៅដំណាក់កាលមួយ គេបានមើលឃើញថា អង្គជំនុំជម្រះអនុញ្ញាតអោយលោក Bizot អង្គុយក្បែរ**ឌុច** នៅពេលគាត់ផ្ដល់សក្ខីកម្ម រហូតទាល់តែសហព្រះរាជអាជ្ញាអន្តរជាតិ លោក **រ៉ូប៊ែរ ពីទី** បានលើកបញ្ហានេះឡើងថា ជាក្ដីកង្វល់ ទើបអង្គជំនុំជម្រះអនុញ្ញាតអោយ**ឌុច**អង្គុយពីក្រោយសហមេធាវីការពារក្ដីរបស់គាត់។ សាក្សីមិនត្រូវបានគេប្រាប់ អំពីសិទ្ធិរបស់គាត់ប្រឆាំងនឹងការឆ្លើយដាក់ពិរុទ្ធភាពលើខ្លួនឯងទេ ហើយក៏មិនបានរំលឹកពួកគេមិនអោយ និយាយអំពីកសិណសាក្សី នៅពេលសម្រាកដំណើរការក្ដីដែរ។

## ៤. ការគ្រប់គ្រងដំណើរការជំនុំជំរះ

***ក្ដីកង្វល់ពាក់ព័ន្ធនឹងការបកប្រែភាសា:*** បញ្ហានៃការបកប្រែភាសាបានក្លាយជាក្ដីកង្វល់ខ្លាំងឡើងៗ កំឡុងពេលដំណើរការក្ដីសប្ដាហ៍នេះ ដោយក្នុងនោះចៅក្រម សហព្រះរាជអាជ្ញា ភាគីការពារក្ដី និងភាគីដើមបណ្ដឹងរដ្ឋប្បវេណី បានធ្វើការកត់សំគាល់នៅដំណាក់កាលខ្លះ ដែលពួកគេមិនបានយល់នូវខ្លឹមសារនៃការបកប្រែ។ លើសពីនេះទៀត នៅក្នុងសាលសាធារណៈ ជាទូទៅអ្នកបកប្រែហាក់ដូចជាប្រញាប់បកបន្ទាត់តាមសាក្សី និងមេធាវី ជាជាងស្នើសុំអោយពួកគេនិយាយយឺតៗ។ ជាពិសេស ជាក់ស្ដែងទាក់ទងនឹងសក្ខីកម្មរបស់លោក Bizot ថ្វីបើគាត់មានវោហារកោសល្យបំផុត តែក៏និយាយលឿនបំផុតផងដែរ។ ករណីស្រដៀងគ្នានេះដែរ ជាញឹកញាប់ការឆ្លងឆ្លើយគ្នារវាងមេធាវីជាតិ និង លោក **អ៊ុច ស៊ន** បានបន្តទៅមុខដោយគ្មានពេលផ្អាកណាមួយចាំបាច់ដើម្បីប្រាកដថា ការបកប្រែពីភាសាអង់គ្លេស និងភាសាបារាំងបានប្រព្រឹត្តទៅដោយសុក្រឹត្យ។ ដោយសារតែប្រព័ន្ធបានអនុម័តនៅតុលាការ គឺសម្រាប់សក្ខីកម្មត្រូវបកប្រែពីខ្មែរ ទៅអង់គ្លេស ទៅភាសាបារាំង និងពីភាសាបារាំង ទៅភាសាអង់គ្លេស ទៅភាសាខ្មែរ (ពោលគឺថាគ្មានការបកប្រែផ្ទាល់ពីភាសាបារាំង ទៅភាសាខ្មែរទេ)។ តំរូវការចំពោះភាគីនានា និងសាក្សីឱ្យនិយាយយឺតៗ គឺ

ជាលក្ខ័ណ្ឌចាំបាច់។ ការពិតគឺថា ពួកគេខកខានម្តងហើយម្តងទៀត ដើម្បីស្នើសុំអោយភាគីនិយាយយឺត១ ដែលធ្វើអោយអង្គជំនុំជម្រះពិបាកកំណត់ថា សំណួរដែលសួរនោះមានភាពច្រំដែល ដោយសារតែភាគីមិនយល់ការបកប្រែ ឬក៏ជាការធម្មតាដោយសារតែពួកគេចង់សួរច្រំដែល១។ ទោះបីជាលោកប្រធានអង្គជំនុំជំរះបានណែនាំជាច្រើនដង ដល់ភាគីនិយាយយឺត១ ច្បាស់ និងប្រយោគខ្លី១ ដើម្បីឱ្យប្រាកដថា ការបកប្រែភាសាអាចដំណើរការទៅដោយរលូនក៏ដោយ ក៏បញ្ហានៃការបកប្រែនៅតែបន្តកើតមាន។ អ្នកបកប្រែគួរត្រូវបានលើកទឹកចិត្ត ដើម្បីបំពេញការងារដោយស្វាហាប់ក្នុងការស្នើសុំភាគីអោយនិយាយយឺត១ និងច្បាស់ ប្រសិនបើពួកគេមានការពិបាកយល់សំណួរ។

***វត្តមានសាធារណៈជន*** **:** នៅសប្តាហ៍ទី២នៃដំណើរការជំនុំជម្រះ**ឌុច** ចំនួនសាធារណជនបានបន្ថយលោះម្តងបន្តិច១ ដោយមានអ្នកចូលរួមក្នុងសាលសាធារណៈតិចជាងកំឡុងពេលចាប់ផ្តើមជំនុំជម្រះក្តី នាសប្តាហ៍ទី១យ៉ាងច្រើន។

## ការគ្រប់គ្រងពេលវេលា

| ថ្ងៃ- កាលបរិច្ឆេទ | ចាប់ផ្តើម | សំរាក- ព្រឹក | អាហារថ្ងៃត្រង់ | សំរាក- រសៀល | បញ្ចប់ | សរុបចំនួនម៉ោង |
|---|---|---|---|---|---|---|
| ច័ន្ទ ០៦-០៤-០៩ | ០៩: ១៥ | ១០:៣០-១០:៥៥ | ១២:០៦-១៣:៤០ | ១៤:៤០-១៥:១០ | ១៦:២០ | ៤ម៉ ៣៦នាទី |
| អង្គារ៍ ០៧-០៤-០៩ | ០៩:១០ | ១០:៣៥-១០:៥៥ | ១២:០៥-១៣:៣៥ | ១៤:៥០-១៥:២០ | ១៦:៣៥ | ៤ម៉ ៥៥នាទី |
| ពុធ ០៨-០៤-០៩ | ០៩:០៩ | ១០:៤៥-១១:១០ | ១២:០០-១៣:៣៥ | ១៤:៤៥-១៥:១០ | ១៦:៣០ | ៤ម៉ ៥៦នាទី |
| ព្រហ. ០៩-០៤-០៩ | ០៩:០៤ | ១០:៤៥-១១:១៣ | ១២:០៧-១៣:៣៩ | ១៤:៤៥-១៥:១០ | ១៦:១៥ | ៤ម៉ ៤៦នាទី |
| ចំនួនម៉ោងជាមធ្យម : ៤ម៉ ៤៨ នាទី<br>ចំនួនម៉ោងសរុបនាសប្តាហ៍នេះ : ១៩ម៉ ១៣នាទី<br>ចំនួនសរុប ម៉ោង ថ្ងៃ និង សប្តាហ៍ នៅសវនាការ : ៣១ម៉ ១៣នាទី នៃ ៧ ថ្ងៃសវនាការ នៃសប្តាហ៍ទី ២ | | | | | | |

---

**អំពីកម្មវិធីអ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម** (″កម្មវិធី″) : ជាកម្មវិធីរបស់អង្គការ the Asian International Justice Initiative (AIJI) ដែលជាកិច្ចសហការរវាង U.C. Berkeley War Crimes Studies Center និង East-West Center ។ កម្មវិធីនេះចេញរបាយការណ៍ប្រចាំសប្តាហ៍ អំពីកិច្ចដំណើរការនីតិវិធីសវនាការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) ឬ តុលាការកាត់ទោសខ្មែរក្រហម។ បច្ចុប្បន្ន កម្មវិធីនេះកំពុងតែឃ្លាំមើលដំណើរការនៃការកាត់ទោសលើសំណុំរឿងរបស់ កាំង ហ្គិចអ៊ាវ ហៅ ឌុច ដែលជារឿងក្តីដំបូងឈានដល់ដំណាក់កាលអង្គជំនុំជម្រះ។

របាយការណ៍ប្រចាំសប្តាហ៍នេះ ត្រូវបានសរសេរដោយក្រុមអ្នកឃ្លាំមើលតុលាការដែលមកពីប្រទេសកម្ពុជា (ចំនួន ៤ រូប) ឥណ្ឌូនេស៊ី សិង្ហបុរី ចិន ស៊ុីស និង អាល្លឺម៉ង់ ។

កម្មវិធីនេះ បានសហការជាមួយមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD) ដើម្បីផ្សព្វផ្សាយរបាយការណ៍នេះ ។លោក- អ្នកអាចរកបាននូវរបាយការណ៍នេះ ជាភាសាខ្មែរ និង អង់គ្លេស នៅក្នុងwww.csdcambodia.org និង http://socrates.berkeley.edu/~warcrime/ ។